ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE

# ការទទួលសាធារណជនចុះឈ្មោះជាអ្នកសង្កេតការណ៍ ក្នុងដំណើរការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ មន្ត្រីអគ្គនាយកដ្ឋានរតនាគារជាតិ សិស្សមន្ត្រីជាន់ខ្ពស់ និងសិស្សមន្ត្រីក្រមការឱ្យចូលរៀននៅសាលាភូមិន្ទរដ្ឋបាល

ស្កេនទីនេះដើម្បីចុះឈ្មោះ

https://forms.gle/Ry1E9o72AWzw87R16

សម័យប្រឡង៖ ថ្ងៃទី ២៣-២៤ ខែវិច្ឆិកា ឆ្នាំ២០២៤

មណ្ឌលប្រឡង៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
**គណៈកម្មការរៀបចំការប្រឡងប្រជែង**

# សេចក្តីជូនដំណឹង
# ស្តីពី
# ការទទួលសាធារណជនចុះឈ្មោះជាអ្នកសង្កេតការណ៍ក្នុងដំណើរការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ មន្ត្រីអគ្គនាយកដ្ឋានរតនាគារជាតិ សិស្សមន្ត្រីជាន់ខ្ពស់សាលាភូមិន្ទរដ្ឋបាល និងសិស្សមន្ត្រីក្រមការសាលាភូមិន្ទរដ្ឋបាល

គណៈកម្មការរៀបចំការប្រឡងប្រជែងសូមជម្រាបជូនសាធារណជនជ្រាបថា៖ ដំណើរការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលចំនួន៤ក្របខណ្ឌ នឹងត្រូវប្រព្រឹត្តទៅនៅសម័យប្រឡងនិងមណ្ឌលប្រឡងដូចខាងក្រោម៖

- សម្រាប់ក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកដ្ឋានរតនាគារជាតិ៖ ប្រព្រឹត្តទៅនៅថ្ងៃសៅរ៍ ទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៤ **នៅមណ្ឌលប្រឡងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**
- សម្រាប់សិស្សមន្ត្រីជាន់ខ្ពស់ និងសិស្សមន្ត្រីក្រមការសាលាភូមិន្ទរដ្ឋបាល៖ ប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៤ **នៅមណ្ឌលប្រឡងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

ដើម្បីជាការបង្ហាញឱ្យឃើញពិតប្រាកដថាការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលទាំង៤ក្របខណ្ឌ ប្រព្រឹត្តទៅដោយឈរលើគោលការណ៍ គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន ប្រសិទ្ធភាព និងអាចទទួលយកបាន គណៈកម្មការរៀបចំការប្រឡងប្រជែង បានសម្រេចឱ្យសាធារណជនស្ម័គ្រចិត្តចំនួន **៥០រូប** ដាក់ពាក្យស្នើសុំចូលរួមសង្កេតការណ៍ដោយផ្ទាល់នៅមណ្ឌលប្រឡង តាមកាលបរិច្ឆេទដូចបានបញ្ជាក់ជូនខាងលើ។

**អ្នកសង្កេតការណ៍ជាសាធារណជន**នឹងត្រូវអញ្ជើញឱ្យតាមដានដំណើរការប្រឡងប្រជែង ចាប់តាំងពីពេលរៀបចំវិញ្ញាសា (ពេលព្រឹក) រហូតដល់បិទមណ្ឌលប្រឡងនៅម៉ោង១៧:៣០នាទី។ **អ្នកសង្កេតការណ៍ជាសាធារណជន**ក៏ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងដំណើរការកំណែនៅសាលាភូមិន្ទរដ្ឋបាលនៅ**ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤** និងថ្ងៃបន្តបន្ទាប់រហូតដល់ដំណើរការប្រឡងប្រជែងត្រូវបានបិទបញ្ចប់។

សាធារណជនអាចដាក់ពាក្យតាមរយៈ QR Code ឬ Link **ចាប់ពីថ្ងៃផ្សាយដំណឹងរហូតដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ត្រឹមម៉ោង១២:០០ថ្ងៃត្រង់។**

**<u>សូមបញ្ជាក់៖</u>** អ្នកដាក់ពាក្យចំនួន**៥០រូប**ដំបូងដែលបានបំពេញព័ត៌មានគ្រប់គ្រាន់និងច្បាស់លាស់នឹងត្រូវបានជ្រើសរើសធ្វើជា **អ្នកសង្កេតការណ៍ជាសាធារណជន**។

ថ្ងៃ ខែ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៤
**គណៈកម្មការរៀបចំការប្រឡងប្រជែង**

ស្កេនទីនេះ ដើម្បីបំពេញពាក្យ

https://forms.gle/afd2ZFw9Ud2FDB6H6

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
គណៈកម្មការរៀបចំការប្រឡងប្រជែង

# បទប្បញ្ញត្តិ
## សម្រាប់អ្នកសង្កេតការណ៍ក្នុងដំណើរការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ មន្ត្រីរតនាគារជាតិ សិស្សមន្ត្រីជាន់ខ្ពស់ និងសិស្សមន្ត្រីក្រមការសាលាភូមិន្ទរដ្ឋបាល
សម័យប្រឡង ថ្ងៃទី២៣-២៤ ខែវិច្ឆិកា ឆ្នាំ២០២៤

ដើម្បីឱ្យការប្រឡងប្រជែងជ្រើសរើសមន្ត្រីកសិកម្មឃុំ មន្ត្រីរតនាគារជាតិ សិស្សមន្ត្រីជាន់ខ្ពស់ និងសិស្សមន្ត្រីក្រមការសាលាភូមិន្ទរដ្ឋបាល ប្រព្រឹត្តទៅប្រកបដោយ គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និង ប្រសិទ្ធភាព គណៈកម្មការរៀបចំការប្រឡងប្រជែងសូមដាក់ចេញនូវបទប្បញ្ញត្តិសម្រាប់អ្នកចូលរួមសង្កេតការណ៍ ដូចខាងក្រោម៖

### ១/ សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍

- មានសិទ្ធិចូលទៅសង្កេតការណ៍ដល់អគារប្រឡង និងនៅខាងក្រៅបន្ទប់ប្រឡង
- ត្រូវប្រើឯកសណ្ឋានសម្គាល់ស្ថាប័នបំពេញការងារឬសំលៀកបំពាក់សមរម្យនិងពាក់កាតសម្គាល់ខ្លួនត្រឹមត្រូវ
- ត្រូវប្រតិបត្តិតាមការណែនាំរបស់គណៈកម្មការរៀបចំការប្រឡងប្រជែង
- ត្រូវទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ ស្របតាមច្បាប់ លិខិតបទដ្ឋាន និងបទប្បញ្ញត្តិដទៃទៀត
- ធានាថា សកម្មភាពសង្កេតការណ៍របស់ខ្លួន មិនបង្កការរំខានដល់មន្ត្រីរៀបចំការប្រឡងប្រជែង និងបេក្ខជន
- ក្នុងករណីសង្កេតឃើញ ឬយល់ឃើញថា មានសកម្មភាពណាមួយមិនប្រក្រតី ត្រូវរាយការណ៍មក អនុគណៈកម្មការដែលគ្រប់គ្រងអ្នកសង្កេតការណ៍ភ្លាម ដើម្បីមានចំណាត់ការសមស្រប
- អាចផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរ ស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួន នៅក្នុងដំណើរការនៃការប្រឡងប្រជែងដល់គណៈកម្មការរៀបចំការប្រឡងប្រជែង។

### ២/ បម្រាមចំពោះអ្នកសង្កេតការណ៍

- ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់គណៈកម្មការរៀបចំការប្រឡងប្រជែង
- ជជែកពិភាក្សា ឬផ្តល់សំណៅឯកសារផ្សេងៗដល់បេក្ខជននៅក្នុងបរិវេណមណ្ឌលប្រឡង
- មិនអនុញ្ញាតឱ្យយកទូរស័ព្ទ ឬគ្រឿងអេឡិចត្រូនិក ថតរូប ថតវីដេអូ ឬថតសំឡេងនៅក្នុងបរិវេណ មណ្ឌលប្រឡងឡើយ
- សរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយដោយគ្មានការអនុញ្ញាត
- យកតាមខ្លួននូវអាវុធ ឬជាតិផ្ទុះ ឬវត្ថុដែលអាចបង្កគ្រោះថ្នាក់ចូលមណ្ឌលប្រឡង
- រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃការប្រឡងប្រជែង។

◀ ក្នុងករណីអ្នកសង្កេតការណ៍មិនអនុវត្តតាមបទប្បញ្ញត្តិ ឬការណែនាំរបស់គណៈកម្មការរៀបចំការប្រឡងប្រជែង អ្នកសង្កេតការណ៍នោះនឹងត្រូវបណ្តេញចេញពីមណ្ឌលប្រឡង និង/ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ៕